# ទ្រឹស្តីបទមួយចំនួននៃប្រូបាប៊ីលីតេ

**ទ្រឹស្តីបទ I :**

បើ A និង B ជាព្រឹត្តិការណ៍ចៃដន្យពីរ នោះ :

$$P(A+B) = P(A) + P(B) - P(AB)$$

**សំរាយបំភ្លឺ:**

A+B កើតមានឡើងនៅពេលណាដែលមានការកើតឡើងនៃព្រឹត្តិការណ៍ណាមួយក្នុងចំណោម ព្រឹត្តិការណ៍ទាំង :

$$A\overline{B}, \overline{A}B, AB$$

ដូច្នេះ : $P(A+B) = P(A\overline{B}) + P(\overline{A}B) + P(AB)$ (1)

$$P(A) = P(A\overline{B}) + P(AB) \Rightarrow P(A\overline{B}) = P(A) - P(AB), (2)$$

$$P(B) = P(\overline{A}B) + P(AB) \Rightarrow P(\overline{A}B) = P(B) + P(AB), (3)$$

ជំនួស (2) និង (3) ក្នុង(1) យើងបាន :

$$P(A+B) = P(A) + P(B) - P(AB)$$

**លក្ខណៈសំគាល់មួយចំនួន :**

- បើ A និង B ជាព្រឹត្តិការណ៍មិនទាក់ទងគ្នា (independent events)

$$P(A+B) = P(A) + P(B) - P(A) * P(B)$$

- បើ A និង B ជាព្រឹត្តិការណ៍ទាក់ទងគ្នា (dependent events)

$$P(A+B) = P(A) + P(B) - P(A)P(B \setminus A)$$

- បើ A និង B ជាព្រឹត្តិការណ៍មិនចុះសំរុងគ្នា (disjoint)

$$P(A+B) = P(A) + P(B) \quad \text{ព្រោះ} \quad P(AB) = 0$$

## ទ្រឹះស្តីបទ II :

ប្រូបាប៊ីលីតេនៃព្រឹត្តិការណ៏ A ដែលកើតឡើងក្រោមលក្ខខ័ណ្ឌនៃការកើតឡើងព្រឹត្តិការណ៏ណាមួយ ក្នុងចំណោមព្រឹត្តិការណ៏មិនចុះសំរុងគ្នា $B_1, B_2, \ldots, B_n$ ដែលបង្កើតជាសាកលកំណត់ដោយ :

$$P(A) = P(B_1)P(A \setminus B_1) + P(B_2)P(A \setminus B_2) + \ldots\ldots + P(B_n)P(A \setminus B_n)$$

$$= \sum_{i=1}^{n} P(B_i)P(A \setminus B_i)$$

**ឧទាហរណ៏ ១:**

នៅក្នុងកេសទីមួយមានចង្កៀង 20 គ្រឿងដែលក្នុងនោះមាន 18 គ្រឿងអាចប្រើប្រាស់បាន ។ នៅក្នុងកេសទីពីរ មានចង្កៀង 10 គ្រឿងដែលក្នុងនោះមាន 9 គ្រឿងអាចប្រើប្រាស់បាន ។ គេយកចង្កៀងមួយពីកេសទីពីរ ដាក់ទៅក្នុងកេសទីមួយ ។ រកប្រូបាប៊ីលីតេដើម្បីអោយចង្កៀងមួយដែលយកចេញពីកេសទីមួយជាចង្កៀងអាចប្រើប្រាស់បាន ?

**ចំលើយ :**

តាង A ជាព្រឹត្តិការណ៏ " ចង្កៀងដែលយកចេញពីកេសទីមួយជាចង្កៀងដែលអាចប្រើប្រាស់បាន " ហើយ $B_1$ ជាព្រឹត្តិការណ៏ " ចង្កៀងដែលយកចេញពីកេសទីពីរដាក់ចូលកេសទីមួយអាចប្រើប្រាស់បាន" និង $B_2$ ជាព្រឹត្តិការណ៏ " ចង្កៀងដែលយកចេញពីកេសទីពីរដាក់ចូលកេសទីមួយមិនអាចប្រើប្រាស់បាន " ។

$$P(B_1) = \frac{9}{10}; P(B_2) = \frac{1}{10}$$

ដូច្នេះប្រូបាប៊ីលីតេដើម្បីអោយចង្កៀងដែលយកចេញពីកេសទីមួយអាចប្រើប្រាស់បានជាប្រូបាប៊ីលីតេមានលក្ខខ័ណ្ឌដែលកំណត់ដោយ $P(A \setminus B_1) = \frac{19}{21}$ ( ក្រោមលក្ខខ័ណ្ឌ $B_1$ ) ។ ដូចគ្នានេះដែរប្រូបាប៊ីលីតេដើម្បីអោយចង្កៀងដែលយកចេញពីកេសទីមួយអាចប្រើប្រាស់បានក្រោមលក្ខខ័ណ្ឌ $B_2$ កំណត់ដោយ :

$$P(A \setminus B_2) = \frac{18}{21}$$

ដូច្នេះ $P(A) = P(B_1)P(A \setminus B_1) + P(B_2)P(A \setminus B_2)$

$$= \frac{9}{10} * \frac{19}{21} + \frac{1}{10} * \frac{18}{21} = 0.9$$

<u>ឧទាហរណ៍</u> :

មានមនុស្សចំនួន 6 នាក់បានចូលលេងល្បែងដ៏សាហាវមួយ ឈ្មោះថា "Roulette Russe" ។ អ្នកទាំង 6 នោះមានឈ្មោះ A,B,C,D,E,F ដែលត្រូវលេងតាមលំដាប់នេះ ។ នៅក្នុងល្បែងនេះគេយកកាំភ្លើង "revolver" ដែលអាចដាក់បាន 6 គ្រាប់ ។ អ្នកទីមួយត្រូវដាក់គ្រាប់កាំភ្លើងមួយគ្រាប់ហើយបង្វិលដុំកាំភ្លើងដោយចៃដន្យរួចបាញ់ខ្លួនឯង ។ បើអ្នកទីមួយមិនស្លាប់អ្នកទីពីរត្រូវដាក់បន្ថែមមួយគ្រាប់ទៀតរួចបាញ់ខ្លួនឯង ។ បើអ្នកទីពីរមិនស្លាប់ទៀតគេនឹងបន្ថែមមួយគ្រាប់ទៀតហើយបើគ្មានអ្នកស្លាប់ទេគេបន្តធ្វើរបៀបនេះរហូតដល់អ្នកទី 6 ។ តើអ្នកមានលេខរៀងទីប៉ុន្មានដែលមានសំណាងជាងគេនៅក្នុងទង្វើនេះ ?

<u>ចំលើយ</u> :

តាង A ជាព្រឹត្តិការណ៍ " បុគ្គល A ត្រូវស្លាប់ "

$\overline{A}$ ជាព្រឹត្តិការណ៍ " បុគ្គល A មិនស្លាប់ "

<u>ទីតាំងទី **1**</u> :

$$P(A)=\frac{1}{6}$$

<u>ទីតាំងទី **2**</u> :

$$P(\overline{A}\cap B)=P(\overline{A})P(B\setminus\overline{A})=\frac{5}{6}*\frac{2}{6}=\frac{5}{18}$$

<u>ទីតាំងទី **3**</u> :

$$P(\overline{A}\cap\overline{B}\cap C)=P(\overline{A})P(\overline{B}\setminus\overline{A})P(C\setminus\overline{A}\cap\overline{B})=\frac{5}{6}*\frac{4}{6}*\frac{3}{6}=\frac{5}{18}$$

<u>ទីតាំងទី**4**</u> :

$$P(\overline{A}\cap\overline{B}\cap\overline{C}\cap D)=P(\overline{A})P(\overline{B}\setminus\overline{A})P(\overline{C}\setminus\overline{A}\cap\overline{B})P(D\setminus\overline{A}\cap\overline{B}\cap\overline{C})$$

$$P(\overline{A}\cap\overline{B}\cap\overline{C}\cap D)=\frac{5}{6}*\frac{4}{6}*\frac{3}{6}*\frac{4}{6}=\frac{5}{27}$$

<u>ទីតាំងទី**5**</u> :

$$P(\overline{A}\cap\overline{B}\cap\overline{C}\cap\overline{D}\cap E)=P(\overline{A})P(\overline{B}\setminus\overline{A})P(\overline{C}\setminus\overline{A}\cap\overline{B})P(\overline{D}\setminus\overline{A}\cap\overline{B}\cap\overline{C})P(E\setminus\overline{A}\overline{B}\overline{C}\overline{D})$$

$$= \frac{5}{6}*\frac{4}{6}*\frac{3}{6}*\frac{2}{6}*\frac{5}{6} = \frac{5^2}{18^2}$$

**ទីតាំងទី 6 :**

$$P(\bar{A}\bar{B}\bar{C}\bar{D}\bar{E}F) = P(\bar{A})P(\bar{B} \setminus \bar{A})P(\bar{C} \setminus \bar{A}\bar{B})P(\bar{D} \setminus \bar{A}\bar{B}\bar{C})P(\bar{E} \setminus \bar{A}\bar{B}\bar{C}\bar{D})P(F \setminus \bar{A}\bar{B}\bar{C}\bar{D}\bar{E})$$

$$= \frac{5}{6}*\frac{2}{3}*\frac{1}{2}*\frac{1}{3}*\frac{1}{6}*\frac{6}{6} = \frac{5}{18^2}$$

យើងសង្កេតឃើញថាទីតាំងដែលល្អបំផុតចំពោះអ្នកលេងទាំងនេះគឺជាទីតាំងចុងក្រោយបំផុត ។ យើងក៏ អាច ផ្ទៀងផ្ទាត់ផងដែរថាក្នុងចំណោមអ្នកលេងទាំង 6 នាក់នេះត្រូវមានម្នាក់ជាអ្នកស្លាប់ បានសេចក្តីថា :

$$P(A \cup B \cup C \cup D \cup E \cup F) = P(A) + P(B) + P(C) + P(D) + P(E) + P(F) = 1$$

**S-plus:**

```
function()
{ b<-1
  z<-1/6
  VeryLuck<-z
   for(i in 2:6)
        {  a<-i/6
            b<-b*((6-i+1)/6)
             z[i]<-a*b
             if( VeryLuck>z[i])
            {
                      VeryLuck <-z[i]
                       Num<-i
              }
          }
      Person<-c(1,2,3,4,5,6)
      z<-cbind(Person,z)
      VeryLuck<-cbind(Num,VeryLuck)
       return(z,VeryLuck)
    }
```

**Result:**

```
      Person           z
[1,]     1         0.16666667
[2,]     2         0.27777778
[3,]     3         0.27777778
[4,]     4         0.18518519
[5,]     5         0.07716049
[6,]     6         0.01543210

$VeryLuck:
    Num  VeryLuck
[1,]   6 0.0154321
```

# រូបមន្ត Bayes

**ឧទាហរណ៏**

នៅក្នុងក្រុមហ៊ុន SIMCO មានបុគ្គលិក 20% មានសញ្ញាប័ត្រ Management ។ ក្នុងចំណោមបុគ្គលិកទាំង 20% នេះ មាន 70% មានប៉ុស្ដ៍អចិន្ត្រៃយ៏ ។ យើងដឹងទៀតថាក្នុងចំណោមបុគ្គលិកដែលគ្មានសញ្ញាប័ត្រ Management 15% មានប៉ុស្ដ៍អចិន្ត្រៃយ ។ បើសិនណាបុគ្គលិកម្នាក់ដែលមាន មានប៉ុស្ដ៍អចិន្ត្រៃយត្រូវបានជ្រើសរើសដោយចៃដន្យពីក្រុមហ៊ុននេះ តើប្រូបាប៊ីលីតេដើម្បីអោយគាត់មានសញ្ញាប័ត្រខាង Management ស្មើប៉ុន្មាន ?

**ចំលើយ** :

បុគ្គលិកទាំងអស់ត្រូវចែកជាពីរផ្នែកមិនចុះសំរុងគ្នា (disjoints) គឺ :

$E_1$ : បុគ្គលិកដែលមានសញ្ញាប័ត្រ Management

$E_2$ : បុគ្គលិកដែលគ្មានសញ្ញាប័ត្រ Management

$$P(E_1)=0.20, P(E_2)=0.80$$

A : បុគ្គលិកម្នាក់ដែលបានជ្រើសរើសដោយចៃដន្យ មានប៉ុស្ដ៍អចិន្ត្រៃយ

$$P(A\setminus E_1)=0.70, P(A\setminus E_2)=0.15$$

អ្វីដែលយើងចង់រកនៅពេលនេះគឺ $P(E_1\setminus A)$ :

$$P(E_1\setminus A)=\frac{P(E_1\cap A)}{P(A)}\Rightarrow P(E_1\cap A)=P(A)P(E_1\setminus A)$$

ម្យ៉ាងវិញទៀត A បង្កឡើងពីព្រឹត្តិការណ៏ពីរដែលមិនចុះសំរុងគ្នា :

$$A=(E_1\cap A)\cup(E_2\cap A)$$

ដូច្នេះ :

$$P(A)=P(E_1\cap A)+P(E_2\cap A)$$

ដោយ $P(E_1\cap A)=P(E_1)P(A\setminus E_1)$ និង $P(E_2\cap A)=P(E_2)P(A\setminus E_2)$

$$\Rightarrow P(E_1\setminus A)=\frac{P(E_1)P(A\setminus E_1)}{P(E_1)P(A\setminus E_1)+P(E_2)P(A\setminus E_2)}$$

រូបមន្តនេះហៅថា រូបមន្ត Bayes ។

ដូច្នេះ : $$P(E_1 \backslash A) = \frac{0.20 * 0.70}{0.20 * 0.70 + 0.80 * 0.15} = 0.5384$$




ជាទូទៅ :

$$P(E_i \backslash A) = \frac{P(E_i)P(A \backslash E_i)}{\sum_{i=1}^{n} P(E_i)P(A \backslash E_i)}$$

រូបមន្តនេះអោយឈ្មោះថា រូបមន្ត Bayes ។

<u>លំហាត់</u> :

១- ប្រូបាប៊ីលីតេដើម្បីអោយយន្តហោះចេញតាមពេលកំណត់ដែលបានព្រៀងនៅលើតារាងពេលវេលា (scheduled flight departs) P(D)=0.83 ។ ដូចគ្នានេះដែរប្រូបាប៊ីលីតេដើម្បីអោយយន្តហោះនេះមកដល់តាមពេលកំណត់ P(A)=0.82 ហើយប្រូបាប៊ីលីតេដើម្បីអោយយន្តហោះនេះចេញតាមពេលកំណត់និងមកដល់តាមពេលកំណត់ P(DA)=0.78 ។ កំណត់ប្រូបាប៊ីលីតេ :
a) P(A\D) ; b) P(D\A)

២- នៅក្នុងភូមិដ៏តូចមួយមាននិស្សិតមួយចំនួនដែលបានបញ្ចប់ការសិក្សាថ្នាក់មធ្យមផ្នែកបច្ចេកទេសកសិកម្ម ហើយដែលយើងបានធ្វើសំរង់ស្ថិតិដូចតទៅ :

| | មានការងារធ្វើ | គ្មានការងារធ្វើ | សរុប |
|---|---|---|---|
| បុរស | 460 | 40 | 500 |
| ស្ត្រី | 140 | 260 | 400 |
| សរុប | 600 | 300 | 900 |

មនុស្សម្នាក់ត្រូវបានជ្រើសរើសពីក្នុងភូមិនេះដោយចៃដន្យដើម្បីទៅសិក្សាបន្តនៅបរទេសសិក្សាស្វែងយល់ ពីបច្ចេកវិជ្ជាមួយចំនួនក្នុងការបង្កើតរោងចក្រមួយក្នុងភូមិនេះ ។ កំណត់ប្រូបាប៊ីលីតេ :

ក- មនុស្សម្នាក់នេះជាបុរសក្រោមលក្ខខ័ណ្ឌដែលគាត់មានការងារធ្វើ

ខ- មនុស្សម្នាក់នេះជស្ត្រីក្រោមលក្ខខ័ណ្ឌដែលគាត់មានការងារធ្វើ

**ចំលើយ** :

តាង M ជាបុរសដែលបានជ្រើសរើស

F ជាស្ត្រីដែលបានជ្រើសរើស

E មនុស្សម្នាក់នេះមានការងារធ្វើ

$$P(M \setminus E)=\frac{P(E\cap M)}{P(E)}=\frac{\frac{460}{900}}{\frac{600}{900}}=\frac{23}{30};P(F \setminus E)=\frac{P(E\cap F)}{P(E)}$$

៣- អ្នកទទួលខុសត្រូវនៃការិយាល័យធុនធានមនុស្សមួយកន្លែងបានតំកល់ទុកប្រវត្តិរូបសង្ខេបរបស់បញ្ញវ័ន្ត ចំនួន 16,000 នាក់ ។ គេបានធ្វើការសិក្សាទៅលើអាយុ និងភេទរបស់បញ្ញវ័ន្តទាំងនេះដូចខាងក្រោម :

| អាយុ \ ភេទ | ប្រុស(M) | ស្រី(F) | សរុប |
|---|---|---|---|
| ក្រោម 30 ឆ្នាំ (A) | 1200 | 1700 | 2900 |
| ចន្លោះ 30 ទៅ 40 ឆ្នាំ (B) | 2600 | 4200 | 6800 |
| ច្រើនជាង 40 ឆ្នាំ (C) | 4000 | 2300 | 6300 |
| សរុប | 7800 | 8200 | 16000 |

ក-បើប្រវត្តិរូបសង្ខេបរបស់បញ្ញវ័ន្ត ម្នាក់ត្រូវបានជ្រើសរើសដោយចៃដន្យ តើប្រូបាប៊ីលីតេដើម្បីអោយមនុស្សម្នាក់នេះមានអាយុតិចជាង 30 ឆ្នាំស្មើប៉ុន្មាន ?

ខ- ប្រូបាប៊ីលីតេដើម្បីអោយមនុស្សស្រីម្នាក់ដែលត្រូវបានជ្រើសរើសដោយចៃដន្យមានអាយុតិចជាង 30 ឆ្នាំ ។

គ- ប្រូបាប៊ីលីតេដើម្បីអោយមនុស្សម្នាក់ដែលត្រូវបានជ្រើសរើសដោយចៃដន្យជាមនុស្សប្រុសនិងមានអាយុច្រើនជាង 40 ឆ្នាំ ?

ឃ- ប្រូបាប៊ីលីតេដើម្បីអោយមនុស្សម្នាក់ដែលត្រូវបានជ្រើសរើសដោយចៃដន្យជាមនុស្សស្រីនិងមានអាយុតិចជាង 40 ឆ្នាំ ?

<u>**ចំលើយ**</u> **:**

ក- $P(A)=\frac{2900}{16000}=0.1813$

ខ- $PA\setminus F)=\frac{P(A\cap F)}{P(F)}=\frac{\frac{1700}{16000}}{\frac{8200}{16000}}=0.2073$

គ- $P(M\cap C)=\frac{4000}{16000}=0.25$ ឬ $P(M\cap C)=P(M)P(C\setminus M)=\frac{7800}{16000}*\frac{4000}{7800}=0.25$

ឃ- $P(F\cap(A\cup B))=P(F\cap A)+P(F\cap B)=0.36875$